ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៚៚៚

GTI GRAND TWINS

ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល
(ខេមបូឌា) ភីអិលស៊ី

*រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក លើកទី៦ របស់ ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី

នាថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ចាប់ពីម៉ោង ០៨:០០ ព្រឹក ដល់ ១១:០០ ថ្ងៃត្រង់ នៅទីស្នាក់ការក្រុមហ៊ុន ដែលមានទីតាំងនៅ ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា លោក **Chen Tsung-Chi** ជាអភិបាល និងជានាយកប្រតិបត្តិរបស់ក្រុមហ៊ុន **ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី** (“**ក្រុមហ៊ុន**”) និងជាតំណាងរបស់លោក យ៉ាង សាវស៊ីន ប្រធានក្រុមប្រឹក្សាភិបាល ត្រូវបាន ប្រគល់សិទ្ធជាប្រធានមហាសន្និបាតភាគហ៊ុនិក លើកទី៦ (“**មហាសន្និបាតភាគហ៊ុនិក**”) និងបានដឹកនាំមហាសន្និបាត ភាគហ៊ុនិករបស់ក្រុមហ៊ុននេះ។

## សមាសភាពចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិក

១. គណៈអធិបតី និងភ្ញៀវកិត្តិយស សវនករឯករាជ្យ និងភ្នាក់ងារបញ្ជិកាមូលបត្ររបស់ក្រុមហ៊ុន
២. គណៈកម្មការរៀបចំដំណើរការមហាសន្និបាតភាគហ៊ុនិក លើកទី៦
៣. ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន អាណត្តិទី២
៤. ភាគហ៊ុនិករបស់ក្រុមហ៊ុនដែលមានរាយនាមក្នុងបញ្ជីរាយនាមភាគហ៊ុនិក ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០*។

* បញ្ជីរាយនាមភាគហ៊ុនិក ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ភាគហ៊ុនិកសរុប មានចំនួន ៥៨៦ នាក់។

- ចំនួនភាគហ៊ុនិកដែលបានចុះវត្តមាន នាថ្ងៃមហាសន្និបាត មានចំនួន ១៤ នាក់ (គិតជាភាគហ៊ុន មានចំនួន ២៨.៤៣៩.៨១៨ ភាគហ៊ុន ស្មើនឹង ៧១,១០% នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។
- ចំនួនភាគហ៊ុនិកដែលអវត្តមាន នាថ្ងៃមហាសន្និបាត ចំនួន ៥៧២ នាក់ (គិតជាភាគហ៊ុន មានចំនួន ១១.៥៦០.១៨២ ភាគហ៊ុន ស្មើនឹង ២៨,៩០ % នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។
- ចំនួនភាគហ៊ុនិកដែលបានចុះឈ្មោះចំនួន ២២ នាក់ (គិតជាភាគហ៊ុន មានចំនួន ៣២.២៩៨.៧៤២ ភាគហ៊ុន ស្មើនឹង ៨០,៧៥ % នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។

## របៀបវារៈកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក

| | |
|---|---|
| ម៉ោង ៨:០០ - ៩:០០ | ការចុះឈ្មោះ |
| ម៉ោង ៩:០០ - ៩:១៥ | ប្រកាសហេតុ |
| ម៉ោង ៩:១៥ - ១០:០០ | បទបង្ហាញស្តីពីរបាយការណ៍លទ្ធផលអាជីវកម្មរបស់ក្រុមហ៊ុន |
| ម៉ោង ១០:០០ - ១០:១៥ | សម្រាកពិសាអាហារសម្រន់ |
| ម៉ោង ១០:១៥ - ១១:០០ | កិច្ចពិភាក្សាលើបញ្ហាផ្សេងៗ (រួមមាន ការបែងចែកភាគលាភ) |
| ម៉ោង ១១:០០ | មតិបញ្ចប់ និងសេចក្តីថ្លែងអំណរគុណ |

ការបែងចែកភាគលាភជូនភាគហ៊ុនិករបស់ក្រុមហ៊ុន ត្រូវបានយល់ព្រម និងអនុម័តដោយភាគហ៊ុនិករបស់ក្រុមហ៊ុន ដូច ខាងក្រោម ៖

ភាគលាភជាសាច់ប្រាក់ចំនួន ២.០០០.០០០.០០០ រៀល ប្រមាណជា ៥០០.០០០ ដុល្លារអាមេរិក ស្មើនឹង ៣៦,០៧% នៃប្រាក់ចំណេញក្រោយបង់ពន្ធប្រចាំឆ្នាំ២០១៩ នឹងត្រូវបែងចែកជូនភាគហ៊ុនិក នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១។

១- ប្រភេទភាគលាភដែលបែងចែក : ជាសាច់ប្រាក់

២- រយៈពេលភាគលាភ : ប្រចាំឆ្នាំ២០១៩

៣- អនុបាតនៃការសងភាគលាភ : ៣៦,០៧% នៃប្រាក់ចំណេញក្រោយបង់ពន្ធ ប្រចាំឆ្នាំ២០១៩

៤- ភាគលាភសរុបដែលបែងចែក : ២.០០០.០០០.០០០ រៀល

៥- ភាគលាភក្នុងមួយឯកតាមូលបត្រមកម្មសិទ្ធ : ៥០ រៀល

៦- កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកត្រូវទទួលបានភាគលាភ: ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១

៧- ការបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ: ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១

ក្នុងមហាសន្និបាតភាគហ៊ុនិកនេះ អង្គប្រជុំបានធ្វើបទបង្ហាញពីខ្លឹមសារលម្អិតនៃរបាយការណ៍ប្រតិបត្តិការ រួមទាំងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន សម្រាប់ដំណាច់ការិយបរិច្ឆេទឆ្នាំ២០១៩ និងត្រីមាសនានា ឆ្នាំ២០២០ នេះ និងកិច្ចពិភាក្សាលើបញ្ហាផ្សេងៗរបស់ក្រុមហ៊ុន។

មហាសន្និបាតភាគហ៊ុនិកនេះ បានបញ្ចប់ទៅនៅវេលាម៉ោង ១១:០០ នាទី ព្រឹក នាថ្ងៃខែឆ្នាំ ដដែល ក្រោមបរិយាកាសទទួលខុសត្រូវខ្ពស់ និងឯកភាពគ្នា។

ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី